# កម្ពុជា ៖ ឃាតកម្មលើអ្នកសារព័ត៌មានធ្វើឲ្យកក្រើកដំណើរការបោះឆ្នោត

*(ញូវយកថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៨) - អង្គការឃ្លាំមើលសិទ្ធិមនុស្សបាននិយាយនៅថ្ងៃនេះថា មិនដល់ទាំងពីរសប្ដាហ៍ផងមុនការបោះឆ្នោតសភាជាតិនៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៨ នេះ បរិយាកាសនយោបាយមានសភាពកាន់តែយ៉ាប់យ៉ឺនឡើង តាមរយៈការលេចចេញនូវឃាតកម្ម ក្នុងរាជធានីភ្នំពេញលើអ្នកសារព័ត៌មានប្រឆាំងគឺលោកឃឹម សម្បូរណ៍ និងកូនប្រុសរបស់លោក។*

*នៅវេលាម៉ោង ៦:៣០ ល្ងាចថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០០៨ លោកសម្បូរណ៍ អាយុ ៤៧ ឆ្នាំ និង កូនប្រុសរបស់លោកឈ្មោះ ខាត់ សារិនភាតា អាយុ ២១ ឆ្នាំ បានទទួលរងការបាញ់ប្រហារជាច្រើនគ្រាប់ដោយជនដែលជិះនៅផ្នែកខាងក្រោយនៃម៉ូតូមួយគ្រឿងក្បែរពហុកីឡដ្ឋានអូឡាំពិច ជាទីកន្លែងដែលលោកសម្បូរណ៍និងកូនប្រុសរបស់លោកហាត់ប្រាណ។ លោកសម្បូរណ៍បាន ស្លាប់នៅកន្លែងកើតហេតុ។ កូនប្រុសរបស់លោកបានស្លាប់ក្នុងមន្ទីរពេទ្យនៅថ្ងៃបន្ទាប់។*

*លោកប្រាដអាដាំ នាយកអង្គការឃ្លាំមើលសិទ្ធិមនុស្សប្រចាំអាស៊ីមានប្រសាសន៍ថា "ដូចយុទ្ធនាការបោះឆ្នោតមុនៗដែរ ឃាតកម្មនេះជាការបញ្ជូនសារប្រាប់អំពីសញ្ញាគ្រោះថ្នាក់ចំពោះការពាក់ព័ន្ធក្នុងនយោបាយប្រឆាំង។"*

*លោកសម្បូរណ៍ ធ្លាប់បានបម្រើការងារជាអ្នកកាសែតឲ្យមនសិការខ្មែរអស់រយៈពេលជាង ១០ ឆ្នាំ ដែលជាកាសែតមួយចូលរួមគាំទ្រគណបក្សសមរង្ស៊ី ដែលជាគណបក្សប្រឆាំង។ កាសែតមនសិការខ្មែរ ជាកាសែតមួយក្នុងចំណោមកាសែតមួយចំនួនក្នុងប្រទេសកម្ពុជា ដែលមិនត្រួតត្រាដោយរដ្ឋាភិបាល ឬគណបក្សប្រជាជនកម្ពុជារបស់នាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលកំពុងកាន់អំណាច និងដែលកំពុងតែត្រួតត្រាស្ថានីយទូរទស្សន៍និងវិទ្យុភាគច្រើន។ លោកសម្បូរណ៍ល្បីល្បាញដោយសារអត្ថបទសារព័ត៌មានរបស់លោកស្ដីពីអំពើពុករលួយ អំពីកិច្ចការនយោបាយ និងការចាប់ឮ្បាមយកដីធ្លី។*

*លោកអាដាំមានប្រសាសន៍ថា " អាជ្ញាធរកម្ពុជាត្រូវចាប់និងនាំខ្លួនជនដែលទទួលខុសត្រូវចំពោះការសម្លាប់លោក ឃឹម សម្បូរណ៍ ដោយមិនត្រូវគិតពីកក្ដីភាពខាងនយោបាយរបស់ជននោះឡើយ។ គួរឲ្យសោកស្ដាយ មានហេតុផលជាច្រើនដែលនាំឲ្យមានការភ័យរន្ធត់ត្រង់ថា លោក ឃឹម សម្បូរណ៍ នឹងក្លាយជាអ្នកសារព័ត៌មានប្រឆាំងម្នាក់ទៀតហើយ ដែលឃាតកម្មរបស់លោក*

*នឹងមិនត្រូវបានគេដោះស្រាយ។*

*ត្រឹមតែមួយខែមុនការធ្វើឃាតលោកឃឹមសម្បូរណ៍ កងរាជអាវុធហត្ថបានចាប់លោកដាំសិទ្ធ និពន្ធនាយកមនសិកាខ្មែរ ដែលឈរឈ្មោះជាបេក្ខជនរបស់គណបក្សសមរង្ស៊ីក្នុងការបោះឆ្នោត បន្ទាប់ពីកាសែតរបស់លោករាយការណ៍ស្តីពីការចោទប្រកាន់លើតួនាទីរបស់រដ្ឋមន្ត្រីការបរទេស បច្ចុប្បន្នអំឡុងរបបខ្មែរក្រហម។ ទោះជាលោកសិទ្ធ ត្រូវបានដោះលែងចេញពីការឃុំឃាំងពីរបីថ្ងៃក្រោយមក និងរដ្ឋមន្ត្រីការបរទេសបានដកពាក្យបណ្តឹងរបស់លោកប្រឆាំងនិពន្ធនាយកក៏ដោយ ក៏ការចោទប្រកាន់ផ្នែកព្រហ្មទណ្ឌលើបទបរិហាកេរ្តិ៍និងការផ្សាយព័ត៌មានមិនពិតនៅតែព្យួរទុកប្រឆាំងនឹងលោកសិទ្ធ ក្រោមមាត្រា ៦២ និង ៦៣ នៃក្រមព្រហ្មទណ្ឌប្រទេសកម្ពុជា។*

*ដំណើរទៅកាន់ការបោះឆ្នោតខែកក្កដាបានកត់សំគាល់តាមរយៈការព្យាយាមយ៉ាងខ្លាំងក្លានិងជាប្រព័ន្ធរបស់គណបក្សប្រជាជនកម្ពុជា ដើម្បីគាបសង្កត់សមាជិកគណបក្សប្រឆាំង ជាពិសេសសមាជិកទាំងឡាយពីគណបក្សសមរង្ស៊ី ដើម្បីឲ្យចុះចូលជាមួយគណបក្សប្រជាជនកម្ពុជា។ ការផ្តល់រង្វាន់ជាតំណែងរដ្ឋាភិបាលដែលមានប្រាក់ខែខ្ពស់ ឬការគំរាមកំហែងនិងវាយបកសងសឹកប្រឆាំងអ្នកដែលមិនព្រមចុះចូល បាននាំឲ្យសមាជិកគណបក្សប្រឆាំងជាច្រើនរយនាក់ចុះចូលជាមួយគណបក្សប្រជាជនអំឡុងពេលយុទ្ធនាការនេះ។*

*ម្នាក់ក្នុងចំណោមអ្នកទាំងឡាយដែលទទួលរងការវាយសងសឹក តាមយុទ្ធនាការចុះចូល គឺលោកទួត សារ៉ុន អ្នកដឹកនាំថ្នាក់មូលដ្ឋានរបស់គណបក្សសមរង្ស៊ីក្នុងខែត្រកំពង់ធំ ដែលស្ថិតនៅក្នុងការឃុំឃាំងជិតបួនខែមកហើយបន្ទាប់ការចាប់ខ្លួនលោកមក។*

*ទាក់ទងនឹងការរំលោភវិធាននៃច្បាប់បោះឆ្នោត គណបក្សនយោបាយចំនួន ១១ ដែលប្រកួតប្រជែងនៅក្នុងការបោះឆ្នោត មិនទទួលបានសិទ្ធិស្មើភាពខាងសារព័ត៌មានទេ ជាពិសេសវិទ្យុនិងទូរទស្សន៍។ ភាគច្រើននៃគ្រឿងផ្សាយព័ត៌មានអេឡិចត្រូនិចក្នុងប្រទេសកម្ពុជាបានផ្តោតគ្របដណ្តប់លើការបោះឆ្នោត ជាភាគច្រើនបំផុតលើការបង្ហាញនិងពិពណ៌នារូបជាវិជ្ជមានរបស់គណបក្សប្រជាជនកម្ពុជា ឬបក្សតែមួយវាយប្រហារលើគណបក្សប្រឆាំងនានា។ នៅថ្ងៃទី ១០ ខែកក្កដា គណៈកម្មាការរៀបចំការបោះឆ្នោតជាតិ(អិនអ៊ីស៊ី) បានចេញការប្រមានដល់ស្ថានីយវិទ្យុ និងទូរទស្សន៍ចំនួន ១៣ ចំពោះការផ្សាយលំអៀងទាក់ទងនឹងការបោះឆ្នោត។ យោងតាមគណៈកម្មា*

ការបោះឆ្នោត ដប់ស្ថានីយនៃស្ថានីយទាំងនេះត្រួតត្រាដោយការផ្សាយកាន់ជើងគណបក្សប្រជាជនកម្ពុជា។

បន្ថែមលើការនាំខ្លួនមករកយុត្តិធម៌នូវឃាតករដែលសម្លាប់លោក ឃឹម សម្បូរណ៍ និងកូនប្រុសរបស់លោក អង្គការឃ្លាំមើលសិទ្ធិមនុស្ស បានអំពាវនាវដល់អាជ្ញាធរកម្ពុជារួចហើយឲ្យអនុវត្តជាបន្ទាន់នូវការកែទម្រង់ដ៏សំខាន់ចាំបាច់ដទៃៗទៀតមុនការបោះឆ្នោត។ ទាំងនេះរាប់បញ្ចូលនូវ ៖

- លប់ចោលការប្តឹងទុកបទចោទប្រហ្មទណ្ឌប្រឆាំងនឹងលោកជាំ សិទ្ធ ។
- ផ្តល់អាជ្ញាប័ណ្ណឲ្យបើកដំណើរការឡើងវិញនូវវិទ្យុអង្គរវត្ត (វិទ្យុអេហ្វអឹម១០៥.២៥) នៅក្នុងខេត្តក្រចេះ ដែលត្រូវបានបិទដោយរដ្ឋាភិបាលនៅក្នុងខែឧសភា ឆ្នាំ២០០៨ បន្ទាប់ពីការលក់ម៉ោងផ្សាយទៅឲ្យគណបក្សប្រឆាំង។
- ដោះលែងលោកទួត សារ៉ុន សមាជិកគណបក្សសមរង្ស៊ីនៅក្នុងខេត្តកំពង់ធំ។
- បញ្ឈប់ការគាបសង្កត់ខុសប្រក្រតីដោយគណបក្សប្រជាជនកម្ពុជា ក្នុងការបង្ខិតបង្ខំមន្ត្រីគណបក្សប្រឆាំងឲ្យរត់ចុះចូលជាមួយគណបក្សប្រជាជនកម្ពុជាមុនការបោះឆ្នោត។ និង
- ធានាឲ្យបាននូវសិទ្ធិស្មើគ្នានិងយុត្តិធម៌ក្នុងការប្រើប្រាស់គ្រឿងផ្សព្វផ្សាយអេឡិចត្រូនិច។

លោកអាដាំ មានប្រសាសន៍ថា "ការបោះឆ្នោតនៅក្នុងប្រទេសកម្ពុជា តែងតែមាននូវអំពើហិង្សា និងការបំភិតបំភ័យជាប់ជានិច្ច។ ទោះជាហិង្សានយោបាយថយចុះតិចជាងការបោះឆ្នោតពីអតីតកាលក៏ដោយ ក៏ការពិតនៅតែបង្ហាញឲ្យឃើញថា អ្នកសារព័ត៌មានប្រឆាំងមួយរូបដែលត្រូវបានគេបាញ់សម្លាប់នៅលើដងវិថីដ៏មមាញឹកមួយនេះ បានបញ្ជូនសេចក្តីវន្ទត់ដល់សហគមន៍អ្នកសារព័ត៌មាន អ្នកគាំទ្រគណបក្សប្រឆាំង និងអ្នកបោះឆ្នោតជាទូទៅ។"